ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៧៧

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០

**សាលដីកា**

លេខ : ៦៥

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធាន
២- លោក វៀល មួន ជាចៅក្រម
៣- លោក ស៊ិន ឌឹម ជាចៅក្រម
៤- លោក ជីវ កេង ជាចៅក្រម
៥- លោក ប្រាក់ គឹមសាន ជាចៅក្រម
៦- លោក សោម សិរីវឌ្ឍ ជាចៅក្រម-របាយការណ៍
៧- លោក ឈឹម ស៊ីផល ជាចៅក្រម
៨- លោក យស់ សូខឿន ជាចៅក្រម
៩- លោក គង់ ភិរុន ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ហុក សុខធុល

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា . ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៦៤"ង" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ សាយ ឆេង (ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ។

ចុងចម្លើយឈ្មោះ ស៊ិន នី (ចុងបណ្តឹងសាទុក្ខ) អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ២១៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះ សាយ ឆេង ប្តឹងមិនសុខចិត្ត និង សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៧៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩៨ របស់ឈ្មោះសាយ ឆេង ប្តឹងទាមទារដី ទំហំ7A90 និង សុំអោយឈ្មោះប៊ុន វ៉ា និង ប្រពន្ធឈ្មោះស៊ិន នី រុះរើផ្ទះចេញពីដីកើតហេតុ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២៤"ក" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះសាយ ឆេង ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ ១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនៈវត្ថុលេខក.ច០០៣៩៧៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ របស់នាយកដ្ឋានសុរិយោដីទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់តាមមាត្រា២ នៃច្បាប់ភូមិបាល ។

៣-ទទួលស្គាល់សិទ្ធិរបស់ដើមចោទឈ្មោះសាយ ឆេង ជាអ្នកមានសិទ្ធិបន្តពីឈ្មោះ ហម រ៉េត លើដីដែលមានប័ណ្ណសំគាល់សិទ្ធិលេខក.ច០០៣៩៧៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ តាមមាត្រា៤១ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យាលក់ ។

៤-នៅពេលសាលក្រមនេះចូលជាស្ថាពរ បង្គាប់អោយឈ្មោះប៊ុន វ៉ា និងឈ្មោះ នី រុះរើសំណង់របស់ខ្លួនអោយអស់ពីដីកើតហេតុ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ពីដើមចោទដែលបានបង់ទុករួចហើយ នៅពេលសាលក្រមចូលជាស្ថាពរ បង្គាប់អោយចុងចម្លើយបង់ពន្ធសមាមាត្រ១% លើតម្លៃដីកើតហេតុ ដែលមានតម្លៃ៧.៧៨០.០០០រៀល ស្មើ៧៦.៨០០រៀល ប្រាក់នេះត្រូវបានអោយដើមចោទបង់ទុកជាមុនសិន ទើបអោយចុងចម្លើយបង់សងវិញជាក្រោយ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង ចុងចម្លើយ ។ ភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាមលើចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៣ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលា-ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះ ស៊ិន នី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធសាលក្រមលេខ១២៤"ក" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាម ចោលជាអសារបង់ ។

៣-បដិសេធបណ្ដឹងសាទុក្ខចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៨របស់ឈ្មោះសាយ ឆេង ចោលជាអសារបង់ ។

៤-ទុកសិទ្ធិអោយឈ្មោះស៊ិន នី ជាចុងចម្លើយប្រើប្រាស់ជាបន្តទៀតរហូតដល់ពេលរដ្ឋត្រូវការដីកើតហេតុនេះ ។

៥-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីង2.550រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

បង្គាប់អោយដើមចោទសងប្រាក់១៣.០០០រៀលទៅអោយចុងចម្លើយពេលណាសាលដីកានេះចូលជាស្ថាពរ ។

៦-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ឈ្មោះសាយ ឆេង ប្ដឹងមិនសុខចិត្ត និង សេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៧៨ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលា-ការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់អ្នកស្រីសាយ ឆេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៣ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូលសំណុំរឿងរដ្ឋប្បវេណីលេខ៦៩ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រីសាយ ឆេង បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រុសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតំរូវអោយអ្នកស្រីស៊ិន នី សងប្រាក់ចំនួន១៩.០០០រៀល នេះទៅអោយអ្នកស្រីសាយ ឆេង វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៤"ង" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋប្បវេណីរបស់តុលាការកំពូលលេខ១៧៨ ចុះថ្ងៃទី២៨ខែកញ្ញា ឆ្នាំ១៩៩៩ ជាសមត្ថកិច្ច ។

២-ទុកសិទ្ធិអោយឈ្មោះស៊ិន នី ជាចុងចម្លើយប្រើប្រាស់ដីទំនាស់ជាបន្តទៅទៀតរហូតដល់រដ្ឋត្រូវការ ។

៣-បង្គាប់អោយអាជ្ញាធរមានសមត្ថកិច្ចធ្វើការកែតំរូវប្លង់សំគាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ក.ច០០៣៩៧៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ ត្រង់ព្រំប្រទល់ខាងជើង គឺកែប្រែពីទល់នឹងថ្នល់ជាតិលេខ ៦A មកនៅត្រឹមទល់នឹងដីចំណីថ្នល់ផ្លូវជាតិលេខ៦A វិញ ចំណុចផ្សេងរក្សាទុកជាបានការដដែល ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ ចំពោះមុខគូក្តី ។ បើផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការបៀបលេខ២២៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបអោយចៅក្រមតុលាការកំពូលធ្វើការស៊ើបអង្កេតបន្ថែម ។ ក្នុងករណីចាំបាច់ ត្រូវចុះពិនិត្យដល់ទីតាំងដីទំនាស់ ។

២-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ២១៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះ សាយ ឆេង ប្ដឹងមិនសុខចិត្ត និង សេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះសាយ ឆេង ។

បានឃើញសារណាតបចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះស៊ិន នី ។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របសតំណាងមហាអយ្យការថា :សាលដីកាសាលាឧទ្ធរណ៍លេខ៦៤"ង" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី សាយ ឆេង (ជាម្ចាស់បណ្ដឹងសាទុក្ខ)នៅពេលសវនាការថា : បានជាខ្លួនប្ដឹងសាទុក្ខ ព្រោះតុលាការសាលាឧទ្ធរណ៍កាត់ពុំត្រឹមត្រូវ ព្រោះដីនេះជាដីរបស់ខ្លួន ខ្លួនទិញមានប្លង់ត្រឹមត្រូវ ហើយនៅលើដីទំនាស់នេះត្រូវបានឈ្មោះ ស៊ិន នី កាន់កាប់រហូតមិនអោយខ្លួនជាម្ចាស់ដីប៉ះពាល់អ្វីបានទេ សូម្បីតែកូនទៅបេះត្រកួនសួមិនបានផង ។ ពីមុនគាត់នៅលើថ្នល់ចាស់មិនទាន់ធ្វើ ដល់ពេលគេធ្វើថ្នល់ គាត់បានកាប់របងដីខ្លួនចូលធ្វើផ្ទះ ។ ខ្លួនសុំអោយតុលាការជួយអោយស៊ិន នី រុះរើផ្ទះចេញពីដីខ្លួន ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ប៊ុន វ៉ា (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលសវនាការថា : ឈ្មោះនេះនិយាយទាំងប៉ុន្មាន គឺមិនពិតទេ ឈ្មោះនេះមានប្លង់ដីមែន តែបានមកដោយការឃុបឃិតជាមួយសុរិយោដី ។ តាមពិតដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩មក ខ្លួនមិនព្រមចេញពីដីនេះទេ បើអោយខ្លួនចេញខ្លួនគ្មានដីនៅទេ ហើយដីនេះជាដីរបស់រដ្ឋ បើរដ្ឋត្រូវការខ្លួនប្រគល់អោយភ្លាម ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្ដឹងសាទុក្ខលេខ២១៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះសាយ ឆេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានដោយយោង

តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទ័ណ្ឌ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចផ្តល់សិទ្ធិឱ្យឈ្មោះ ស៊ិន នី ជាចុងចម្លើយប្រើប្រាស់ដីទំនាស់ជាបន្តទៀតរហូតដល់រដ្ឋត្រូវការដោយអាងហេតុថា ចុងចម្លើយបានរស់នៅតាំងពីឆ្នាំ១៩៧៩ រហូតដល់សព្វថ្ងៃជាដីចំណីថ្នល់ជាតិលេខ៦A គឺជាដីរបស់រដ្ឋគ្រប់គ្រងនោះជាការពុំត្រឹមត្រូវទេ ពីព្រោះដីដែលចុងចំលើយសង់ផ្ទះក្រោយឆ្នាំ១៩៧៩ គឺជាដីដែលរដ្ឋបានឈូសឆាយយកធ្វើផ្លូវជាតិលេខ៦A អស់ហើយ រួមមានទាំងផ្ទះជាច្រើនទៀតក៏ត្រូវរុះរើនៅឆ្នាំ១៩៩៤ ទៅរស់នៅកន្លែងផ្សេងទៀតដែរ ហើយដោយឡែកចុងចម្លើយបានសង់ផ្ទះលើដីទំនាស់នៅឆ្នាំ១៩៩៤ ប៉ុណ្ណោះ ។ ម្យ៉ាងទៀតតាមលិខិតបញ្ជាក់ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកមេឃុំតាំងក្រាំងបញ្ជាក់ថា ឆ្នាំ១៩៩៤នោះរដ្ឋដេញផ្ទះអនាធិបតេយ្យលើចិញ្ចើមថ្នល់អស់ ស្រាប់តែចុងម្លើយរំកិលផ្ទះកូនរបស់ខ្លួនពង្រីកផ្ទះធំជាន់លើដីរបស់ឈ្មោះ ហម រ៉េត ដែលលក់ឱ្យដើមចោទ ហើយរដ្ឋបានដេញជាជំហានទី២ទៀត ប៉ុន្តែចុងចម្លើយពុំស្តាប់អាជ្ញាធរ និង ប៉ូលីសដែលនៅក្រុមអន្តរាគមន៍រៀបចំដងផ្លូវឡើយ ។ ដូច្នេះរដ្ឋពិតជាត្រូវការដីចំណីថ្នល់ដែលជាដីទំនាស់ប្រាកដមែន ។

- យល់ឃើញថាចុងចម្លើយរស់នៅលើដីចំណីថ្នល់ជាតិលេខ៦A ដែលរដ្ឋបានដេញហើយ ប៉ុន្តែពុំព្រមចេញ ហើយការរស់នៅនេះក៏ធ្វើឱ្យបិទមុខដីរបស់ដើមចោទព្រមទាំងបានបង្កទំនាស់ជាបន្តបន្ទាប់ជាមួយដើមចោទ រហូតដល់បង្កជាបទល្មើសព្រហ្មទណ្ឌ ធ្វើឱ្យបាត់បង់សិទ្ធកាន់កាប់ប្រើប្រាស់របស់ដើមចោទលើដីទំនាស់ដែលនៅបាំងមុខដីកម្មសិទ្ធរបស់ខ្លួន ។ ដូច្នេះផ្ទះរបស់ចុងចម្លើយធ្វើឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈផង ហើយធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ដើមចោទផង ដែលតាមសេចក្តីប្រកាសស្តីពី វិធានការលប់បំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លីលេខ06ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល សំណង់លើដីចំណីថ្នល់ របស់ចុងចម្លើយ ក៏ត្រូវតែរុះរើចេញដែរ ។ ចុងចម្លើយពុំមានសិទ្ធកាន់កាប់ និង គ្រប់គ្រងដីទំនាស់នេះទេ ។

- យល់ឃើញថាតាមការព្រមព្រៀងរបស់ដើមចោទ នៅពេលសវនាការនេះក៏ដូចជាក្នុងសារណាបន្ថែមរបស់ខ្លួន ដើមចោទបានសំរេចផ្តល់ដី១កន្លែង ដែលបានទិញពីឈ្មោះលុយ រៀម ស្ថិតនៅភូមិតាំងក្រាំង ឃុំជាលា ស្រុកបាធាយ ខេត្តកំពង់ចាម ដែលមានទំហំ១០ម x ២០ម មានព្រំប្រទល់ខាងជើងទល់ជើងទំនប់ ខាងត្បូងទល់ដី រៀម សីឡា ខាងកើតទល់ដីរៀម សិឡា ខាងលិចទល់ដី រឿន អាត ឱ្យចុងចម្លើយដើម្បីសង់ផ្ទះរស់នៅតទៅ ។ ដូច្នេះតុលាការកំពូលគប្បីសំរេចតាមការយល់ព្រមនេះ ។

- យល់ឃើញថាប័ណ្ណសំគាល់សិទ្ធិលេខ កច០០៣៩៧៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ របស់ដើមចោទមានការភ័ន្តច្រឡំអំពីព្រំប្រទល់ខាងជើងដែលដាក់ថា ទល់នឹងផ្លូវជាតិលេខ៦ ដែលគប្បីតុលាការកំពូលបង្គាប់ឱ្យអង្គភាពជំនាញកែតម្រូវទៅជា "ទល់នឹងដីចំណីផ្លូវជាតិលេខ៦" វិញ ។

- យល់ឃើញថាសាលដីកាវដ្តប្បវេណីលេខ៦៤ "ង" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈ ខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីទំពោះមុខ ដូច្នោះ**

១- ទទួលបណ្តឹងសាទុក្ខលេខ២១៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះ សាយ ឆេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាវដ្តប្បវេណីលេខ៦៤ "ង" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្គាប់អោយឈ្មោះស៊ិន នី ជាចុងចម្លើយរុះរើផ្ទះ និង ការ្យទាំងពួងចេញពីដីទំនាស់ (តាមគំនូសប្លង់ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០២ របស់ចៅក្រមតុលាការកំពូល) ។

៤- ផ្តល់ដីមួយកន្លែងទំហំ១០ម គុណ២០ម ស្ថិតនៅភូមិតាំងក្រាំង ឃុំជាលា ស្រុកបាធាយ ខេត្តកំពង់ចាម មានព្រំប្រទល់ ខាងជើងទល់ដីជើងទំនប់ ខាងត្បូងទល់ដី រៀម សីឡា ខាងកើតទល់ដីរៀម សីឡា ខាងលិចទល់ដីរឿន អាត ឱ្យចុងចម្លើយសង់ផ្ទះរស់នៅតាមការយល់ព្រមរបស់ដើមចោទ ។

៥- បង្គាប់ឱ្យអង្គភាពជំនាញមានសមត្ថកិច្ច កែតម្រូវព្រំប្រទល់ដីខាងជើង លើប័ណ្ណសំគាល់សិទ្ធលេខ កច០០៣៩៧៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ ទៅជា " ចំណីផ្លូវជាតិលេខ៦ " ។

៦- របអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលដើមចោទបានបង់ទុកនៅតុលាការកំពូល គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្គីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀលហើយ តម្រូវអោយចុងចម្លើយសងប្រាក់១៩.០០០រៀល នេះទៅដើមចោទវិញ ។

៧- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ។